**ស្ថានទូតបារាំងប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីថ្លែងការណ៍របស់សហប្រធាននៃមិត្តសាលាក្តី

សហប្រធាននៃមិត្តសាលាក្តីសូមធ្វើសេចក្តីថ្លែងការណ៍ក្នុងនាមម្ចាស់ជំនួយនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដូចខាងក្រោម៖

**ម្ចាស់ជំនួយ**

- គាំទ្រយ៉ាងខ្លាំងក្លាចំពោះតួនាទីរបស់ អ.វ.ត.ក ដែលបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិក្នុងការផ្តល់យុត្តិធម៌ជូនប្រជាជនកម្ពុជាសម្រាប់អំពើឃោរឃៅដែលប្រព្រឹត្តឡើងក្រោមរបបខ្មែរក្រហម។
- ស្វាគមន៍ចំពោះសន្ទុះនៃការងាររបស់ អ.វ.ត.ក និងកត់សម្គាល់ពិសេសអំពីសវនាការដែលកំពុងប្រព្រឹត្តទៅនៅ អ.វ.ត.ក ចំពោះ កាំង ហ្គេចអ៊ាវ ហៅ ឌុច សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ការធ្វើមនុស្សឃាត និង ការធ្វើទារុណកម្ម។
- គាំទ្រជំហររបស់រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិក្នុងការបន្តដំណើរការសាលាក្តីប្រកបដោយភាពត្រឹមត្រូវ ប្រសិទ្ធផល និងឆាប់រហ័ស។
- ស្វាគមន៍វឌ្ឍនភាពដែលសម្រេចបាននៅក្នុងការប្រជុំរួមរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិក្នុងការពង្រឹងការគ្រប់គ្រងធនធានមនុស្សរបស់ អ.វ.ត.ក ក្នុងនោះរួមមានវិធានការប្រឆាំងនឹងអំពើពុករលួយផងដែរ។
- កត់សម្គាល់ថារាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានធ្វើឲ្យមានវឌ្ឍនភាពយ៉ាងច្រើនក្នុងការបង្កើតវិធានការប្រឆាំងអំពើពុករលួយនៅក្នុង អ.វ.ត.ក។
- ជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិព្រមព្រៀងលើរចនាសម្ព័ន្ធដែលអាចធានាលក្ខខណ្ឌតម្រូវនៃនីតិវិធីត្រឹមត្រូវតាមច្បាប់ ក្នុងនោះរួមមានការការពារប្រឆាំងនឹងការសងសឹកណាមួយចំពោះការរាយការណ៍កំហុសឆ្គងដោយសុច្ចចិត្តដូចដែលមាននៅក្នុងសេចក្តីថ្លែងការណ៍រួមថ្ងៃទី២៣ ខែកុម្ភៈ។

- រៀបចំខ្លួនជាស្រេចក្នុងការជួយ អ.វ.ត.ក សម្រេចបាននូវគោលដៅដ៏សំខាន់របស់ខ្លួន។
- ក្នុងន័យនេះ  សូមស្វាគមន៍វិភាគទានថ្មីរបស់រដ្ឋាភិបាលជប៉ុនក្នុងការផ្ដល់ថវិកាជំនុំជម្រះក្ដីដែលជាចំណែករបស់កម្ពុជាក៏ដូចជាថវិកាបន្ថែមដែលបំពេញនូវកង្វះខាតរបស់ភាគីកម្ពុជាសម្រាប់ចំណាយប្រតិបត្តិការរបស់  អ.វ.ត.ក  និងរៀបចំខ្លួនជាសម្រេចក្នុងការកោះអញ្ជើញប្រជុំមិត្តរបស់សាលាក្ដីនៅក្នុងពាក់កណ្ដាលខែឧសភា ឆ្នាំ២០០៩។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩

| | |
|---|---|
| Jean-François DESMAZIÈRES | Katsuhiro SHINOHARA |
| ឯកអគ្គរដ្ឋទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា | ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា |